**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋបាលជលផល**

លេខ: ៦៣៤១២............ជផ

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖សំណើសូមជួយអន្តរាគមន៍ជូនទៅរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភា ដើម្បីសុំការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពី វិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

**ជូនភ្ជាប់**៖- ឯកសារកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ជាភាសាខ្មែរចំនួន០១ច្បាប់ និងជាភាសាអង់គ្លេស០១ច្បាប់
- សេចក្តីថ្លែងហេតុស្តីពីកិច្ចព្រមព្រៀងស្តីពី វិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ជាភាសាខ្មែរចំនួន០១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន**ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ត្រូវបានរៀបចំឡើងនិងដាក់ឱ្យប្រើប្រាស់ ដោយអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ (FAO) កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៩។ គោលបំណងសំខាន់នៃកិច្ចព្រមព្រៀងនេះ គឺដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ក្នុងកម្រិតសកល កម្រិតតំបន់ និងក្នុងរដ្ឋនីមួយៗ តាមរយៈការអនុវត្តវិធានការត្រួតពិនិត្យនាវានេសាទនិងនាវាពាក់ព័ន្ធនឹងការធ្វើនេសាទនៅតាមកំពង់ផែឡើងត្រីនៃរដ្ឋជាសមាជិក។ ម្យ៉ាងទៀតការអនុវត្តតាមកិច្ចព្រមព្រៀងនេះ គឺជាការចូលរួមគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ពិសេសការចូលរួមការការពារធនធានជលផលសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យនិងជួយអន្តរាគមន៍ដោយសេចក្តីអនុគ្រោះ។

សូម**ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃច័ន្ទ ១១កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

ង៉ែត ជាសាន

**ចម្លងជូន៖**
- នាយកដ្ឋាននីតិកម្មកសិកម្ម
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
  - ដើម្បីជ្រាបជាព័ត៌មាន -
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានៈ អគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ... /Fax (855) 23 215 470 www.fia.gov.kh
Address: #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Morn, Phnom Penh, Cambodia P.O.Box 582, Fax (855) 23 215 470 www.fia.gov.kh